

# បងប្អូនស្រីវីរជនវៀតណាម (ហាយបាជឹងជាឈ្មោះ ផ្លូវមួយក្នុងទីក្រុងហូជីមិញ)

Vu Thi Kim Ha

Dasol Kim

Let's Read

The Asia Foundation



នេះជារឿងមួយដែលបានកើតឡើងជាង ២០០០ ឆ្នាំមុនមក ម៉្លេះ។ កាលដើមឡើយ ប្រទេសវៀតណាម រស់នៅជាប្រទេសឯករាជ្យមួយ ដែលគ្រប់គ្រងដោយរាជវង្សហុង។ បន្ទាប់មក រាជវង្សហាន់បានរួបរួមជាប្រទេសចិនតែមួយ ហើយចិន បានក្លាយទៅជាប្រទេសដ៏ខ្លាំងក្លាហើយវាយប្រហារយក វៀតណាមមកកាន់កាប់។ ដោយកាលនោះប្រទេសវៀតណាម នៅទន់ខ្សោយនៅឡើយ ក៏ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ រាជវង្សហាន់នៅពេលនោះទៅ។ អំឡុងពេលនោះវៀតណាម ត្រូវបានគេហៅថាណាំបៀត។ រាជវង្សហាន់បានកាន់កាប់និងបែងចែកណាំបៀតទៅជា៣តំបន់។ ក្រោយមកហាន់បានជាន់ឈ្លីលើវប្បធម៌ប្រពៃណីរបស់ណាំបៀត ដោយបានដុតកំទេចចោល

ស្គរប្រពៃណីនៃណាំបៀតដែលធ្វើពីលង្ហិន វត្ថុមានតម្លៃនៅណាំបៀត មានស្នែងដំរីនិងគុជខ្យង ព្រមទាំងគ្រាប់ធញ្ញជាតិក៏ត្រូវបានដណ្តើមយកទៅទាំងអស់។ ការរស់នៅរបស់ប្រជាជននាពេលនោះកាន់តែក្រីក្រ និងទុរគតទៅៗ។



ស៊ូឌីងគឺជាមន្ត្រីម្នាក់ដែលរាជវង្សហាន់ គេត្រូវបានបញ្ជូនមកគ្រប់គ្រងចាអូជី ដែលជា តំបន់មួយក្នុងចំណោម តំបន់ទាំង៣នៃណាំបៀត។ ប្រជាជនស្អប់ស៊ូឌីងដោយសារគេជាមនុស្សកោងកាច និងលោភលន់ហួសហេតុ។ ដោយមិនអាចទ្រាំនឹងការជិះជាន់ហួសហេតុនេះបានតទៅទៀត ប្រជាជននៅតំបន់ទាំង៣បានក្រោកឈរឡើង ធ្វើការបះបោរជាហូរហែ។ ការងើបបះបោរ របស់ប្រជាជនក្នុងតំបន់ចាអូជី បានទទួលជោគជ័យ ហើយប្រជាជនទទួលបានមកវិញនូវគ្រាប់ធុញ្ញជាតិ ដែលបាត់បង់នោះត្រឡប់មកវិញ ដែលធ្វើឱ្យពួកគេរួចផុតពីភាពស្រេកឃ្លានមួយរយៈ តែពួកគេនៅមិនទាន់ទទួលបានសេរីភាពពេញលេញពីការគ្រប់គ្រងរបស់រាជវង្សហាននៅឡើយទេ។

ស៊ូឌីង បានបង្កកម្លាំងយោធា ដើម្បីតាមចាប់អ្នកដែលប្រឆាំង នឹងការគ្រប់គ្រងរបស់គាត់ ហើយធ្វើទារុណកម្មពួកគេ។ នាសម័យនោះតំបន់មេរីងហ្សន់ មានមនុស្សម្នាក់ដែលជាអ្នកកាន់កាប់ដីជាច្រើនជាងគេឈ្មោះ ឡាក់ចាង គាត់មានកូនស្រីភ្លោះដ៏ស្រស់ស្អាតពីរនាក់ ដែលមានឈ្មោះថា «ជឹងចាក់» និង «ជឹងនី»។ បងប្អូនស្រី ទាំងពីរ មានទេពកោសល្យផ្នែកវិជ្ជាប្រយុទ្ធ។ ពួកគេខិតខំរៀនវិជ្ជាប្រយុទ្ធនេះតាំងពីកុមារភាពមកម្ល៉េះ ព្រោះតាំងចិត្តចង់ស្តារប្រទេសខ្លួន ដែលត្រូវបានរាជ្យវង្សហាន់ដណ្តើមទៅនោះ យកមកវិញ ។ ក្រោយមក អ្នកទាំងពីរក៏ធំពេញវ័យ ក្លាយជាស្ត្រីដ៏ស្រស់ស្អាត និងថ្លៃថ្នូរដែលទទួលការស្រឡាញ់ និងការគោរពពីមនុស្សជាច្រើន។



បុរសវ័យជំទង់ម្នាក់ ឈ្មោះធីសាក រស់នៅតំបន់ជូជីអេនដែលនៅជាប់និងតំបន់ម៉ែលរីងហ្សន់។ ធីសាក គឺជាកូនប្រុសរបស់មេបញ្ជាការមួយរូប គេជាមនុស្សដែលមានប្រាជ្ញា និងមានជំនាញក្នុងការប្រយុទ្ធម្នាក់។ មិនយូរប៉ុន្មាន ធីសាក់ ក៏បានជួបនឹងបងប្អូនស្រីត្រកូលជឹង ហើយមានចិត្តគំនិតដូចគ្នាទៅនឹងជឹងចាក់ដែលជាបងស្រី ។ ជឹងចាក់និង ធីសាកបានស្រលាញ់គ្នានិងបានរៀបការជាមួយគ្នា។ ពួកគេគិតពីរឿងទាមទារយកឯករាជ្យរបស់ប្រទេស មកវិញ។ ពួកគេបានប្រមូលផ្តុំមនុស្សម្នា ហើយបានបង្កើតគម្រោង ការបះបោរដ៏ធំមួយ។ ប្រជាជនជឿលើភាពជាអ្នកដឹកនាំរបស់ពួកគេ ។ ប៉ុន្តែផែនការបះបោរនេះត្រូវបានឮដល់ត្រចៀករបស់ស៊ូឌីង។ ស៊ូឌីង បាន

ចាប់ធីសាក់ ហើយធ្វើទារុណកម្មគេយ៉ាងឃោរឃៅ ។ ស៊ូឌឹង
គំរាមប្រជាជនណាំបៀតថានឹងសម្លាប់ ធីសាក់ ចោល ប្រសិនបើ
ពួកគេមិនបញ្ឈប់សកម្មភាពប្រឆាំងនេះ។ ប៉ុន្តែប្រជាជននៅ
ណាំបៀតមិនបានខ្លាចរអាពីការគំរាមនោះឡើយ។ ទីបំផុត
ធីសាក ត្រូវគេសម្លាប់យ៉ាងឃោរឃៅ។ ជឹងចាក់និង ជឹងនី
ទទួលអារម្មណ៍តក់ស្លុតយ៉ាងខ្លាំង នៅពេលឮថា ធីសាក់ បាន
ស្លាប់។

ជឹងនីបានស្រែកយ៉ាងខ្លាំងថា៖ «បងស្រី ពួកយើងត្រូវតែ
សងសឹក! ពិតជាមិនអាចទ្រាំតទៅទៀតទេ!»

ជឹងចាក់ ខាំធ្មេញសង្កត់ចិត្ត រួចពោលយ៉ាងមុតមាំថា៖
«យើងត្រូវតែ ធ្វើផែនការដែលបានគ្រោងជាមួយ ធីសាក
ឱ្យបានសម្រេច! ត្រូវដេញសត្រូវចេញពីប្រទេសយើង ទើប
វិញ្ញាណរបស់ប្តីខ្ញុំទៅឋានសួគ៌ស្ងប់ចិត្ត!»



ជំនួសឱ្យ ធីសាក ជឹងចាក់បានក្លាយជាមេដឹកនាំនៃប្រជាជនណាំបៀត។ ពួកគេទទួលបានកម្លាំងគាំទ្រពីភូមិជិតខាងដែលដឹកនាំដោយស្ត្រីឆ្នើមម្នាក់ឈ្មោះថា វេចន។ ជឹងចាក់បានរួបរួម ប្រជាជនដែលនៅភ័យខ្លាច។ ប្រជាជន រំជួលចិត្ត ហើយបានចូលរួមកម្លាំងម្តងទៀត កម្លាំងរបស់ពួកគេបានកើនឡើងច្រើនជាងមុន។ នៅទីបំផុតពួកគេត្រៀមខ្លួនរួចស្រេចសម្រាប់ចេញចេញធ្វើសង្គ្រាម។



«អ្នកនាងមេទ័ព លោកធីសាក់ បានស្លាប់ទៅហើយ តើយើងទាំងអស់គ្នាគួរចេញប្រយុទ្ធដោយប្រើឈុតកាន់ទុក្ខមែនទេ?»
«មិនមែនទេ! យើងត្រូវពាក់អាវសឹករបស់យើង! ទាមទារយកប្រទេសជាតិមកវិញគឺជារឿងចំបងបំផុតនៅពេលនេះ។ យើងត្រូវបង្ហាញឱ្យទ័ពសត្រូវឃើញពីអំណាចរបស់យើង!» ជឹងចាក់និយាយ ។
ជឹងចាក់បានប្តូរសំលៀកបំពាក់កាន់ទុក្ខ ទៅជាអាវសឹក។ ជឹងនី និងបងស្រី បានឡើងជិះលើខ្នងដំរីហើយសំដៅទៅខាងមុខក្បួន។ សំឡេង បូ ... បូ ... បូ ... បូបូ បានបន្លឺឡើង គ្រប់ទិសទី។ វាគឺជាសញ្ញាប្រកាសច្បាំងរបស់កងទ័ព

ណាំបៀត។ បងប្អូនស្រីជឹង បានវាយប្រហារប្រាសាទ ឡីឡាវ ដែលជាទីតាំងស៊ូឌីង ដោយភាពក្លាហាន ។ ប្រាសាទត្រូវបាន កម្ទេចភ្លាមៗ បងប្អូនស្រីជឹង និងប្រជាជនបានកាន់កាប់វិញ នូវប្រាសាទចំនួន ៦៥ ដែលគេបានដណ្តើមយកទៅ ក្នុងមួយ ប៉ព្រិចភ្នែក។ ទាហានរបស់ប្រទេសហាន់ ចោលគ្រប់យ៉ាង ហើយរត់យកតែខ្លួន។ ស៊ូឌីង ភិតភ័យនឹងទាហានវៀតណាម ហើយបានកាត់សក់ បន្លំខ្លួនធ្វើជាទាសករហើយរត់គេចខ្លួន ទៅប្រទេសខ្លួនវិញ។ ការបះបោររបស់បងប្អូនស្រីត្រកូល ជឹង គឺទទួលបានជោគជ័យយ៉ាងខ្លាំង។ មនុស្សគ្រប់គ្នាបាន អបអរសាទរចំពោះជ័យជម្នះនេះ ហើយបានលើក ជឹងចាក់ ជា ព្រះមហាក្សត្រីគ្រប់គ្រងប្រទេស។

ជឹងចាក់ បានសាងសង់រាជវាំងមួយឈ្មោះ «កូវ៉ាយ» ដើម្បី កសាងភាពអស្ចារ្យរបស់ប្រទេស និងគ្រប់គ្រងប្រជាជនឱ្យ បានល្អ។ ជឹងនី បានបណ្តុះបណ្តាលពួកឧត្តមសេនីយ៍និង នាយទាហាន ដើម្បីជាកម្លាំងការពារប្រទេសឱ្យខ្លាំងក្លាផងដែរ។ ប្រជាជនរស់នៅដោយសុភមង្គល ពួកគេធ្វើកសិកម្មដោយសុខ សន្តិភាព។



ប៉ុន្តែសន្តិភាពនេះគង់មិនបានយូរទេ។
អធិរាជនៃប្រទេសហាន់បានចាត់ទុកការ បះបោររបស់បងប្អូនស្រីត្រកូលជឹងនេះ ថាជាការបះបោរដ៏សម្បើម ហើយទ្រង់បានរៀបចំការឈ្លានពានទ្រង់ទ្រាយធំមួយមកលើណាំបៀត។ គាត់បានបញ្ជូនកងទ័ពដ៏ច្រើនសន្ធឹកដែលដឹកនាំដោយឧត្តមសេនីយ៍ ម៉ាវ៉ុន ទៅវាយយកណាំបៀត។ កងទ័ពដែលបញ្ជូនមកមានចំនួនច្រើនសន្ធឹក ច្រើនជាងចំនួនប្រជាជនសរុបនៃណាំបៀតទៅទៀត។ ប្រជាជន ណាំបៀតប្រយុទ្ធដោយសេចក្តីក្លាហាន ប៉ុន្តែពួកគេមិនអាចយកឈ្នះកងទ័ពហាន់ដែលមានចំនួនច្រើន រួមនិងអាវុធល្អៗរបស់ហាន់នោះទេ។ កំលាំងប្រយុទ្ធចាប់ផ្តើមចុះខ្សោយបន្តិចម្តងៗ មនុស្ស

និងទាហានជាច្រើននាក់បានបាត់បង់ជីវិត។
បងប្អូនស្រីត្រកូលជីង សម្រេចចិត្តដកថយ ដោយមិនអាចតទល់ពីការវាយប្រហារដ៏ខ្លាំងក្លារបស់ប្រទេសហាន់បាន។ បន្ទាប់មក ពួកគេបាននាំទាហានទៅលាក់ខ្លួននៅក្នុងព្រៃភាគខាងជើងដែលនៅឆ្ងាយពីតំបន់មេលីង។ អស់រយៈពេលជាងមួយឆ្នាំ ម៉ាវ៉ុន នៅតែបន្តព្យាយាមដេញតាមសម្លាប់បងប្អូនស្រីត្រកូលជីងមិនឈប់ ។
ប្រជាជននៅណាំបៀតត្រូវបានវាយប្រហារឥតឈប់ឈរដោយកងទ័ពហាន់ ហើយបានរស់នៅយ៉ាងវេទនា។ មេបញ្ជាការដែលចាញ់នៅក្នុងសង្គ្រាមនោះ បាននាំទាហានរបស់ពួកគេត្រឡប់ទៅស្រុកកំណើតវិញ។ គេបានបោះបង់ការបេសកកម្មនេះហើយ។
តែបងប្អូនស្រីជីងមិនបានលះបង់គំនិតប្រឆាំងតបតនឹងកងកម្លាំងសត្រូវឡើយ។ ថ្វីបើកងទ័ពមានចំនួនតិចយ៉ាងណាក៏ដោយ ក៏ពួកគេនៅតែបន្តប្រយុទ្ធយ៉ាងស្វិតស្វាញដល់ដង្ហើមចុងក្រោយដែរ។ កងទ័ពហាន់វាយប្រហាររឹតតែខ្លាំងក្លាឡើង ទីបំផុតដំរីរបស់បងប្អូនស្រីជីងបានងាប់ក្នុងសមរភូមិ។



ទាហានបាក់ទឹកចិត្ត ហើយទីបំផុតបងប្អូនស្រីជឹងបានចាញ់ការប្រយុទ្ធ។ បងប្អូនស្រីជឹងទាំងពីរ ឈរនៅមាត់ទន្លេជាមួយគ្នា។

«បងស្រី តើពេលនេះពួកយើងត្រូវធ្វើបែបណា? ប្រជាជនស្លាប់ច្រើនណាស់។ ខ្ញុំមើលមិនឃើញផ្លូវចេញឡើយ» ជឹងនីនិយាយទាំងទឹកភ្នែក។

«កុំយំ ពេលនេះពួកយើងមិនអាចធ្វើអ្វីបានទៀតទេ! តែយើងក៏មិនអាចឱ្យសត្រូវចាប់បាននោះដែរ រឹតតែមិនអាចធ្វើជាទាសកររបស់ពួកគេឡើយ។»

បងប្អូនស្រីជឹងទាំងពីបានចាប់ដៃគ្នាហើយបានលោតទៅក្នុងទន្លេ។ នេះជាការបញ្ចប់ជីវិតយ៉ាងក្រៀមក្រំរបស់អ្នកទាំងពីរ។

ចាប់តាំងពីពេលនោះមកវៀតណាមស្ថិតនៅក្រោមការគ្រប់គ្រង
របស់ចិនអស់រយៈពេលយ៉ាងយូរ ប៉ុន្តែប្រជាជនវៀតណាម
តែងតែមានសម្ទុះចិត្តមោះមុតព្រោះ ពួកគេចងចាំពីវីរភាពរបស់
បងប្អូនស្រីត្រកូលជឹងនៅក្នុងចិត្តរបស់ពួកគេជានិច្ច។
ពួកគេបានក្លាយជាវីរជនដ៏គួរឱ្យគោរពរបស់វៀតណាម។
បងប្អូនស្រីជឹងបានបង្ហាញក្ដីស្រឡាញ់នៃប្រទេសនិងកម្លាំង
របស់ស្ត្រីតាមរយៈជីវិតក្លាហានរបស់ពួកគេ។
នៅទីក្រុងហូជីមិញប្រទេសវៀតណាមមានផ្លូវមួយហៅថា
«ហាយបាជឹង» ដើម្បីជាការគោរពដល់បងប្អូនស្រីត្រកូលជឹង។
សូម្បីតែពេលនេះកូនចៅជំនាន់ក្រោយនៃប្រទេសវៀតណាម
កំពុងតែធំឡើងដោយមានឧត្តមគតិរបស់បងប្អូនស្រីជឹងទាំងពីរ
នៅជាមួយផងដែរ។




រហូតមកទល់ពេលនេះអ្នកវិទ្យាសាស្ត្របានរុករកចំណេះដឹង
ប្រាជ្ញានិងបច្ចេកវិទ្យាទំនើបតែមិនអាចរកឃើញភពផ្សេង
ដែលមនុស្សរស់នៅបានដូច «ភពផែនដី» ឡើយ។ តែមនុស្ស
ទាំងនោះមិនបានឈប់រកភពផ្សេងដែលមានជីវិតរស់នៅ
ដូចទៅនិងភពផែនដីនុះឡើយ។ គ្មាននរណា និងគ្មានក្បួន
ណាដែលអាចរាប់ផ្កាយជាច្រើននៃភពនីមួយៗឡើយ។ ភព
ដែលមនុស្សរស់នៅបាន គឺភពផែនដីតែមួយគត់។ វាជារឿង
អស្ចារ្យបំផុត។ ពិតណាស់អារម្មណ៍រំជួលចិត្តនូវពេលដែល
បានដឹង។ ពិសេសនៅពេលបានធ្វើការជាមួយនារីប្រទេស
ផ្សេងៗនៅជុំវិញពិភពលោកដែលមករស់នៅក្នុងប្រទេសកូរ៉

រឹតតែទទួលអារម្មណ៍រំជួលចិត្តបំផុត។ ភពផែនដីតែមួយ ទោះយើងជាជនជាតិណាក្ដីតែជា «គ្រួសារផែនដី»។ គ្រួសារត្រូវទុកចិត្តគ្នា ពឹងផ្អែកលើគ្នា និងជួយគ្នាទៅវិញទៅមក។ គ្រួសារជាអ្នកដែលយើង ឱបមុនគេ សើចដាក់មុនគេ និងលះបង់ឱ្យមុនគេ។ គ្រួសារគឺរួមទុក្ខជាមួយគ្នា ជម្នះការលំបាកជាមួយគ្នា ត្រូវដើរទៅជាមួយគ្នា។ ខ្ញុំកោតសរសើរដល់អស់អ្នកដែលបានសរសេរស្នាដៃដ៏អស្ចារ្យតាមរយៈការងារសៀវភៅកុមារ«រួមទាំងគ្នា រួមទាំងអស់គ្នា»។ ដោយសារតែអ្នកចូលរួមទាំងអស់នោះសុទ្ធតែត្រូវចិញ្ចឹម បីបាច់កូន ត្រូវធ្វើកិច្ចការផ្ទះ មើលថែបម្រើមនុស្សចាស់ក្នុងផ្ទះ និងធ្វើការងារជាដើម ទោះបីជាមានការនឿយហត់យ៉ាងណាក្ដីពួកគេក៏បានបញ្ចប់កាងារដោយជោគជ័យ។ ពិតជាមិនងាយស្រួលឡើយសំរាប់ការសរសេរជាភាសាកូរ៉េសំរាប់អ្នកមិនទាន់ចេះច្បាស់ភាសានៅឡើយ។ យ៉ាងណាក្ដី ការសរសេរបង្កប់ឥទ្ធិពលដែលមិនអាចប្រៀប ទៅនឹងការនិយាយរាប់រយដង។ ឥទ្ធិពលបង្ហាញឱ្យឃើញច្បាស់នូវចិត្តគំនិត ឥទ្ធិពលនៃសមាសភាពក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ឥទ្ធិពលក្នុងការអប់រំកូនឱ្យបានល្អ មានឥទ្ធិពលទាំងអស់នេះ ខ្ញុំសូមជំរុញឱ្យគម្រោងនេះកើតមានឡើងរឹតតែច្រើន ដែលផ្ដល់មោទនភាពនិងក្ដីសង្ឃឹមដល់ស្ត្រីចំណាកស្រុកជាច្រើននិងគ្រួសាររបស់ពួកគេ។ អ្នកនិពន្ធ៖ ណូក្យ៉ុងស៊ីល



រហូតមកទល់ពេលនេះអ្នកវិទ្យាសាស្ត្របានរុករកចំណេះ
ដឹង,ប្រាជ្ញានិងបច្ចេកវិទ្យាទំនើបតែមិនអាចរកឃើញភពផ្សេង
ដែលមនុស្សរស់នៅបានដូច ភពផែនដី ឡើយ។តែមនុស្ស
ទាំងនោះមិនបានឈប់រកភពផ្សេងដែលមានជីវិតរស់នៅដូចទៅ
និងភពផែនដីនុះឡើយ។
គ្មាននណា,និងគ្មានក្បួនណាដែលអាចរាប់ផ្កាយជាច្រើននៃភព
និមួយៗឡើយ។តែភពដែលមនុស្សរស់នៅបានគឺភពផែនដី
តែមួយគត់, អស្ចារ្យបំផុត
ពិតណាស់អារម្មណ៍រំជួលចិត្តនូវពេលដែលបានដឹងនិង។
ពិសេសនៅពេលបានធ្វើការជាមួយនារីប្រទេសផ្សេងៗនៅ

ជុំវិញពិភពលោកដែលមកប្រទេសកូរ៉េតែទទួលអារម្មណ៍
រំជួលចិត្តបំផុត។ភពផែនដីតែមួយ ទោះយើងជាជនជាតិណាក្តី
តែជា គ្រួសារផែនដី ។
គ្រួសារត្រូវទុកចិត្តគ្នា,ពឹងផ្អែកលើគ្នា,និងជួយគ្នា
ទៅវិញទៅមក។
គ្រួសារគឺអោបមុនគេ, សើចដាក់មុនគេ,និងលះបង់អោយ
មុនគេ។
គ្រួសារគឺរួមទុកជាមួយគ្នា,ជំនះការលំបាកជាមួយគ្នា,ត្រូវដើរទៅ
ជាមួយគ្នា។
ខ្ញុំកោតសរសើរដល់អស់អ្នកដែលបានសរសេរស្នាដៃដ៏អស្ចារ្យ
តាមរយៈការងារសៀវភៅកុមារ"រួមទាំងគ្នា រួមទាំងអស់គ្នា"។
ដោយសារតែអ្នកចូលរួមទាំងអស់នោះសុទ្ធតែត្រូវចិញ្ចឹម
បីបាច់កូន,ត្រូវធ្វើកិច្ចការផ្ទះ,មើលថែបម្រើរមនុស្សចាស់ក្នុង
ផ្ទះ,និងធ្វើការងារជាដើមទោះបីជាមានការនឿយហត់យ៉ាងណា
ក្តីក៏បានបញ្ចប់កាងារបានជោគជយ័។ពិតជាមិនងាយស្រួល
ឡើយសំរាប់ការសរសេរជាភាសាកូរ៉េសំរាប់អ្នកមិនទាន់ច្បាស់
ទៅនិងភាសារនៅឡើយ។
យ៉ាងណាក្តីការសរសេរបង្កប់ឥទ្ធិពលដែលមិនអាចប្រៀបទៅ
និងការនិយាយរាប់រយដង។
ឥទ្ធិពលបង្ហាញអោយឃើញច្បាស់នៅចិត្តគំនិត
ឥទ្ធិពលនៃសមាសសភាពក្នុងការប្រាស្រ័យទាក់ទងជាមួយអ្ន

កដីទៃ
ឥទ្ធិពលក្នុងការអប់រំកូនអោយបានល្អ
មានឥទ្ធិពលទាំងអស់នេះ
ខ្ញុំសូមជំរុញឱ្យគម្រោងនេះកើតមានឡើងរឹតតែច្រើន,ដែលផ្តល់មោទនភាពនិងក្តីសង្ឃឹមដល់ស្ត្រីចំណាកស្រុកជាច្រើននិងគ្រួសាររបស់ពួកគេ។ អ្នកនិពន្ធ,ណ្វាក៉្យងស៊ីល

, 머니그램재단이 후원하였습니다.

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*슬픈 쯩 자매의 전설 (The Legend of Vietnam's Heroes - the Trung Sisters)*, Author: Vu Thi Kim Ha. Illustrator: Dasol Kim. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC-BY-NC-SA-4.0.

This work is a modified version of the original story. © The Asia Foundation, 2019. Some rights reserved. Released under CC-BY-NC-SA-4.0.
Contributing translators: Nasema Zeerak